ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តបន្ទាយមានជ័យ

លេខ៖......៤៣០/១៦.....ខ.ស.ប

បន្ទាយមានជ័យ. ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧

យោងលិខិត៧៧៩ សដណ.គជអប ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៦ របស់លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ( គ.ជ.អ.ប ) ។

រដ្ឋបាលខេត្តបន្ទាយមានជ័យនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០១៧ ។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញ ថ្លៃនៅគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា ៣ប្រភេទ៖

- ប្រភេទទី១៖អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារនិងការងារបេតុង ...។ល។)
- ប្រភេទទី២៖អ្នកទទួលការ ការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ...។ល។)
- ប្រភេទទី៣៖អ្នកទទួលការឯកទេស(អ្នកទទួលការដែលមានឧបករណ៍និងជំនាញបច្ចេកទេសសម្រាប់ការងារ ពិសេសឧទាហរណ៍អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេសនិងសម្ភារៈបរិក្ខារគ្រប់គ្រាន់ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជី ឈ្មោះអ្នកទទួលការដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងទៅ នឹង ប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិច០២កិច្ចសន្យាក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យ ដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និង វាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជីព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ការអនុវត្តការងារទាន់ពេលវេលានិងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោងដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផល

អាសយដ្ឋានៈ ផ្លូវជាតិលេខ៥ សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ទូរស័ព្ទ-ទូរសារ (Phone-Fax) ០៥៤ ៧១០០៦២ Email banteaymeanchey1@gmail.com mean.vannak@bmc.ncdd.gov.kh Web . www.bmc.ncdd.gov.kh

នៃការវាយតម្លៃនេះអនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូនអភិបាលខេត្តដើម្បីពិនិត្យនិងសម្រេច។ អ្នកទទួលការទាំងឡាយណាដែលត្រូវបាន រកឃើញថាមានការពាក់ព័ន្ធនឹងការឃុបឃិតស៊ីគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិ ជាផ្លូវការ អ្នកទទួលការនោះនឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

ទទួលបានសេចក្តីជូនដំណឹងនេះបើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមប្រញាប់ មកដាក់ពាក្យសុំចុះ ឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការនិងវិនិយោគ នៃសាលាខេត្ត ចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ **ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង ១៧ល្ងាច** ។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមកក៏ត្រូវដាក់ ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីអ្នក ទទួលការដោយឥតបង់ថ្លៃតាមអាសយដ្ឋានអ គារជួរក្រោយក្នុងបរិវេណសាលាខេត្តបន្ទាយមានជ័យ ឬអាចទាញយកពីគេហទំព័ររបស់គ.ជ.អ.ប ។

អភិបាលខេត្ត

**សួន បវរ**

**ចម្លងជូន**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ក្រុមប្រឹក្សាខេត្ត

«ដើម្បីគោរពជូនជ្រាប»

- គ្រប់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់

«ដើម្បីផ្សព្វផ្សាយ»

- ឯកសារ កាលប្បវត្តិ